ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៥ លេខ ២ | មេសា - មិថុនា ឆ្នាំ២០១១ | តម្លៃ ១.៥០០៛

# ជម្រុញកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា៖ ទស្សនៈ និងអាទិភាពគោលនយោបាយ ទទួលបានពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១១[1]

សន្និសីទចក្ខុវិស័យកម្ពុជាប្រចាំឆ្នាំលើកទី៥ បានប្រារព្ធឡើងកាលពីថ្ងៃទី១៦ មីនា ២០១១ នៅសណ្ឋាគារភ្នំពេញ។ សន្និសីទនេះ បានអញ្ជើញតំណាងជាន់ខ្ពស់មកពីខាងរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ សហគមន៍ស្រាវជ្រាវ និងសង្គមស៊ីវិល មកជួបជុំគ្នាដើម្បីធ្វើការពិភាក្សាអំពីប្រធានបទ "ជម្រុញកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា៖ កាលានុវត្តភាព និងបញ្ហាប្រឈម"។ នៅក្នុងសុន្ទរកថាគន្លឹះបើកសន្និសីទ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្ដែងការអបអរសាទរចំពោះ វិទ្យាស្ថាន CDRI និងធនាគារ ANZ Royal ដែលបានសហការគ្នាផ្តួចផ្តើមគំនិតបង្កើតសន្និសីទប្រចាំឆ្នាំដ៏មានសារៈសំខាន់នេះ ហើយសម្ដេច បានថ្លែងថា សន្និសីទនេះប្រារព្ធឡើងចំពេលវេលាល្អ និងមានភាពពាក់ព័ន្ធនឹងកាលៈទេសៈបច្ចុប្បន្ន។

អត្ថបទនេះ បូកសរុបពីចំណុចសំខាន់ៗនៃសន្និសីទចក្ខុវិស័យ មានជាអាទិ៍ ក្របខ័ណ្ឌច្បាប់និងស្ថាប័ននៅកម្ពុជា ទម្រង់ទូទៅនៃកម្លាំងពលកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដោយផ្ដោតលើទស្សនៈ និងអាទិភាពគោលនយោបាយនានា ដែលវាគ្មិន និងអ្នកចូលរួមទាំងឡាយបានលើកឡើង។ បទបង្ហាញនានា ក្នុងសន្និសីទចក្ខុវិស័យ អាចរកបាននៅក្នុងគេហទំព័ររបស់វិទ្យាស្ថាន CDRI: www.cdri.org.kh។



*សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំលើកទី៥ កាលពីថ្ងៃទី១៦ មីនា ២០១១*

កម្ពុជា កំពុងបន្តដំណើររើបឡើងវិញយ៉ាងខ្លាំងក្លាពីវិបត្តិសេដ្ឋកិច្ចពិភពលោក ដោយមានអត្រាកំណើនសេដ្ឋកិច្ចដែលរំពឹងថានឹងកើនឡើងពី ៥,៩% នៅឆ្នាំ២០១០ ដល់ ៦-៧% នៅឆ្នាំនេះ។ វិស័យជម្រុញកំណើនតាំងពីដើមរៀងមករបស់កម្ពុជា និងវិស័យនានាដែលរងការប៉ះទង្គិចធ្ងន់ធ្ងរ ក្នុងអំឡុងពេលមានវិបត្តិនោះ កំពុងរើបឡើងវិញគួរឲ្យកត់សម្គាល់ ហើយថែមទាំងបានជួយជម្រុញកំណើនសេដ្ឋកិច្ចនាពេលបច្ចុប្បន្នទៀតផង។ វិស័យឧស្សាហកម្មមានដំណើរការខ្លាំងជាងគេ ដោយសម្រេចបានកំណើន ១៣,៥% នៅឆ្នាំ២០១០ ធៀបនឹង -៩,៥% នៅឆ្នាំ២០០៩។ ដោយឡែក វិស័យកាត់ដេរក្នុងពេលដ៏ខ្លីខាងមុខរំពឹងថាអាចកើនលឿនដល់កម្រិតដូចនៅមុនពេលមានវិបត្តិ ដោយបង្កើតការងារបានដល់ ៥៥.០០០ គឺស្ទើរតែស្មើនឹងចំនួនការងារដែលបានបាត់បង់ក្នុងអំឡុងពេលមានវិបត្តិ។ ស្ថិតិកំណើន មានលក្ខណៈល្អ ប៉ុន្តែរចនាសម្ព័ន្ធសេដ្ឋកិច្ចនៅបង្កក្ដីបារម្ភដែល

១ អត្ថបទនេះ រៀបរៀងដោយ Benjamin C. R. FLOWER កម្មសិក្សាការីផ្នែកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ដោយផ្អែកលើបទបង្ហាញនានាក្នុងសន្និសីទចក្ខុវិស័យ ។

## មាតិកា

ជម្រុញកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា៖ ទស្សនៈ និងអាទិភាពគោលនយោបាយ ទទួលបានពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១១ ........ ១
ការវិវត្តថ្មីៗក្នុងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ នៅកម្ពុជា ........ ៦
អង្កេតស្ដីពីសមត្ថភាព និងការត្រៀមខ្លួនរបស់ឃុំក្នុងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍មូលដ្ឋាន៖ លទ្ធផលបឋម .. ១២
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៨
— ស្ថានភាពក្នុងប្រទេស ........ ២០
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ២៨

ពីព្រោះត្រូវពឹងផ្អែកលើវិស័យកាត់ដេរ និងទេសចរណ៍ ដែលងាយរងគ្រោះដោយសារហានិភ័យពីខាងក្រៅ។ ការពឹងផ្អែកខ្លាំងពេកលើតម្រូវការពីខាងក្រៅនូវមុខផលិតផលមួយចំនួនតូច អាចគ្រោះថ្នាក់ខ្លាំងណាស់ ប្រសិនបើតម្រូវការធ្លាក់ចុះ ឬលក្ខខណ្ឌពាណិជ្ជកម្មប្រែប្រួលផ្សេងៗ។ ដើម្បីកាត់បន្ថយហានិភ័យនេះ និងកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ពេលអនាគត ប្រទេសកម្ពុជាត្រូវឆក់ឱកាសនេះ ដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ច ដោយពង្រីកសកម្មភាពទាក់ទងច្រើនវិស័យ បង្កើតសកម្មភាពថ្មីៗក្នុងវិស័យនីមួយៗ បង្កើនខ្សែសង្វាក់តម្លៃបន្ថែម និងចូលទៅក្នុងទីផ្សារថ្មីៗផ្សេងទៀត។

ឈរលើជោគជ័យសម្រេចបានក្នុងពេលកន្លងមក និងក្នុងការស្វែងរកដំណោះស្រាយគោលនយោបាយសមស្រប សម្រាប់អនាគត សន្និសីទចក្ខុវិស័យឆ្នាំ២០១១ បានផ្ដោតលើចំណុចសំខាន់ៗ ៣ ដែលទាមទារឱ្យមានការចូលរួមរបស់រដ្ឋាភិបាល ដើម្បីធានាឲ្យមានកំណើនខ្ពស់ ប្រកបដោយសមធម៌ និងនិរន្តរភាព គឺមាន៖ (១) គោលនយោបាយពង្រឹងបរិយាកាសច្បាប់ និងស្ថាប័នសម្រាប់ពាណិជ្ជកម្មនិងវិនិយោគ ការលើកទឹកចិត្តដល់វិស័យនាំចេញថ្មីៗឲ្យមានលក្ខណៈចម្រុះច្រើនមុខ និងមានកំណើនប្រកបដោយសមធម៌ (២) គោលនយោបាយលើកកម្ពស់ធនធានមនុស្សកម្ពុជាឲ្យក្លាយជាកត្តាជម្រុញផង និងជាអ្នកទទួលផលប្រយោជន៍ផងពីពិពិធកម្មសេដ្ឋកិច្ច និង (៣) គោលនយោបាយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដ៏ចាំបាច់ សម្រាប់ជួយទ្រទ្រង់មាគ៌ាអភិវឌ្ឍន៍របស់កម្ពុជា។

## ការកសាងបរិយាកាសច្បាប់ និងស្ថាប័ន ឲ្យមានលក្ខណៈអំណោយផល

ក្នុងរយៈពេលមធ្យម ពាណិជ្ជកម្ម និងវិនិយោគ រំពឹងថានឹងកើនឡើង (ក្រាហ្វិក ១)។ គោលនយោបាយសមស្របអនុវត្តដោយស្ថាប័នមានតម្លាភាពល្អ នឹងពង្រឹងកំណើននេះ ហើយញ៉ាំងឲ្យវាមានចីរភាព និងសមធម៌ថែមទៀត។ ភាពអំណោយផលនៃបរិយាកាសស្ថាប័ន គោលនយោបាយ និងច្បាប់ សំខាន់ខ្លាំងណាស់ក្នុងការជម្រុញកម្ពុជាឲ្យមានផលិតផល និងសេវាកម្មនាំចេញថ្មីៗ មានទីផ្សារក្នុងតំបន់ភូមិសាស្ត្រថ្មីៗ និងឲ្យបង្កើនតម្លៃខ្សែសង្វាក់ផលិតកម្ម។ ការជួយឲ្យវិស័យទើបស្ទុះឡើង (ឧ. កសិកម្ម) ដើម្បីទទួលបានផលចំណេញពីកំណើនពាណិជ្ជកម្ម និងវិនិយោគ អាចជម្រុញយ៉ាងច្រើនដល់ការកាត់បន្ថយភាពក្រីក្រ ហើយគោលនយោបាយផ្ដោតចំវិស័យទាំងនេះ អាចញ៉ាំងឲ្យលទ្ធផលសម្រេចបានប្រសើរបំផុត។

គោលនយោបាយពាណិជ្ជកម្ម ជាសមាសភាគស្នូលមួយនៃយុទ្ធសាស្ត្រពិពិធកម្មរបស់រដ្ឋាភិបាល។ ក្នុងក្របខ័ណ្ឌនៃអភិក្រមគ្របដណ្ដប់លើវិស័យពាណិជ្ជកម្ម (SWAp) គេព្យាយាមបញ្ជ្រាបគោលនយោបាយពាណិជ្ជកម្ម ដោយធ្វើការសម្របសម្រួលរវាងធនធានរដ្ឋាភិបាល និងធនធានរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីឲ្យគោលនយោបាយមានឥទ្ធិពលខ្លាំងបំផុត។ ក្របខ័ណ្ឌនេះសំដៅដោះស្រាយទាំងឧបសគ្គជាក់លាក់ និងឧបសគ្គមានលក្ខណៈជាប្រព័ន្ធដែលរារាំងពិពិធកម្មសេដ្ឋកិច្ច។ ទាក់ទងនឹងឧបសគ្គមានលក្ខណៈជាប្រព័ន្ធ គេឃើញមានការរួមកម្លាំងគ្នាកសាងសមត្ថភាពស្ថាប័ននានា ដើម្បីជម្រុញការអនុវត្តគោលនយោបាយពាណិជ្ជកម្មឲ្យ

ក្រាហ្វិក ១. ទម្រង់ពាណិជ្ជកម្មកម្ពុជា និងវិនិយោគផ្ទាល់ពីបរទេស (FDI)







ប្រភព៖ បទបង្ហាញក្នុងសន្និសីទចក្ខុវិស័យឆ្នាំ២០១១

បានសមស្រប។ តួយ៉ាង គម្រោងពាណិជ្ជកម្ម UNDP មួយ បានផ្តោតលើការកសាងសមត្ថភាព និងការសម្របសម្រួលរវាងនាយកដ្ឋានមួយចំនួនរបស់ក្រសួងពាណិជ្ជកម្ម។ ក្របខ័ណ្ឌគោលនយោបាយតាមវិស័យជាក់លាក់មួយចំនួន ក៏បានដាក់អនុវត្តដែរ ជាអាទិ៍ គោលនយោបាយជម្រុញផលិតកម្មស្រូវ និងការនាំចេញស្រូវ ដែលបានដាក់ចេញដោយសម្តេចនាយករដ្ឋមន្ត្រី ក្នុងខែកក្កដា ២០១០ គឺជាកិច្ចប្រឹងប្រែងដំបូងបង្អស់ ដើម្បីឆ្លើយតបចំពោះតម្រូវការផ្ទាល់របស់វិស័យនាំចេញជាក់លាក់នីមួយៗ នៅក្រោមក្របខ័ណ្ឌនៃ SWAp។

គោលនយោបាយអាចមានប្រសិទ្ធភាព លុះណាតែបានកំណត់ត្រឹមត្រូវពីឧបសគ្គនានា ហើយបានផ្តោតលើទម្រង់សេដ្ឋកិច្ច-សង្គមកិច្ច និងប្រជាសាស្ត្រខុសៗគ្នានៅកម្ពុជា។ វេទិការដ្ឋាភិបាល-វិស័យឯកជន បានជួយសម្រួលដល់កិច្ចសន្ទនានៅកម្រិតជាតិរវាងរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីធានាថា គោលនយោបាយពាណិជ្ជកម្ម មានបង្ហាញពីធាតុពិតនៃការផ្លាស់ប្តូរសេដ្ឋកិច្ចនៅកម្ពុជា។ ប៉ុន្តែ ការទាក់ទាញអ្នកពាក់ព័ន្ធក្នុងវិស័យឯកជនឲ្យមកចូលរួម ត្រូវជួបបញ្ហាចោទ ដោយសារសហគ្រិន តែងធ្វើការគិតគូរសម្រាប់រយៈពេលខ្លី ចំណែកឯពិពិធកម្មគឺជាយុទ្ធសាស្ត្ររយៈពេលវែង។

ដើម្បីតម្រឹមចំណុចទាំងពីរនេះ រដ្ឋាភិបាលគួរផ្តល់គ្រឿងលើកទឹកចិត្តដល់វិស័យឯកជនឲ្យខំគិតគូរ សម្រាប់រយៈពេលវែង និងជួយដល់ការធ្វើពិពិធកម្ម។ ម្យ៉ាងទៀតត្រូវមានការវិភាគ និងស្រាវជ្រាវស៊ីជម្រៅផ្នែកគោលនយោបាយ ដើម្បីជួយឲ្យគោលនយោបាយពាណិជ្ជកម្មមានបង្ហាញពី តម្រូវការរបស់ជនងាយរងគ្រោះបំផុតក្នុងសង្គម។ ក្នុងគោលដៅនេះ យុទ្ធសាស្ត្រធ្វើរោគវិនិច្ឆ័យលើសមាហរណកម្មពាណិជ្ជកម្មឆ្នាំ២០០៧ បានជួយកំណត់វិស័យនាំចេញចំនួន ១៩ ដែលមានសក្តានុពលកាត់បន្ថយភាពក្រីក្របានច្រើន។ រដ្ឋាភិបាលត្រូវបង្កើនសមត្ថភាពស្រាវជ្រាវគោលនយោបាយ នៅក្នុងបណ្តាញស្ថាប័នស្រាវជ្រាវនៅកម្ពុជា ដើម្បីពង្រឹងការយល់ដឹងពីទំនាក់ទំនងរវាងការអភិវឌ្ឍវិស័យនាំចេញ និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព។ ធនធានសម្រាប់ការស្រាវជ្រាវ ក៏ត្រូវយកមកប្រើប្រាស់ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃគោលនយោបាយ សំដៅចូលរួមចំណែកជម្រុញកំណើនប្រកបដោយសមធម៌ ដោយជួយឲ្យគោលនយោបាយអាចដាក់អនុវត្តបានសមស្រប និងសម្រេចបានពេញលេញតាមគោលបំណង។

សមត្ថភាពស្ថាប័ន ជាកត្តាដ៏សំខាន់សម្រាប់លើកកម្ពស់បរិយាកាសវិនិយោគនៅកម្ពុជា។ តំបន់សេដ្ឋកិច្ចពិសេស (SEZ) ជាឧទាហរណ៍ជាក់ស្តែងមួយ ដែលបញ្ជាក់ពីជោគជ័យនៃគោលនយោបាយបច្ចុប្បន្នរបស់កម្ពុជា ក្នុងការទាក់ទាញវិនិយោគឯកជនច្រើនៗ ប្រសិនបើឧបសគ្គខាងស្ថាប័នត្រូវបានដោះស្រាយ។ ប្រទេសកម្ពុជា និង SEZ មានក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិស្រដៀងគ្នា ប៉ុន្តែ នីតិវិធីអនុវត្តច្បាប់នៅក្នុង SEZ មានភាពលឿនជាង និងងាយស្មានដឹងមុនជាង។ កំណើនចំនួនវិនិយោគ នៅ SEZ បញ្ជាក់ច្បាស់ថា វិនិយោគិនឲ្យតម្លៃខ្ពស់ទៅលើដំណើរការអនុវត្តច្បាប់ប្រកបដោយតម្លាភាព។ ដូច្នេះ កិច្ចការសំខាន់គឺត្រូវសិក្សាពីក្របខ័ណ្ឌច្បាប់ដែលមានដំណើរការល្អក្នុង SEZ និងទាញយកបទពិសោធន៍នេះ ធ្វើជាការសន្និដ្ឋានទូទៅសម្រាប់សេដ្ឋកិច្ចកម្ពុជា។

ប្រព័ន្ធតុលាការទន់ខ្សោយ ជាឧបសគ្គខាងស្ថាប័នចំបងមួយចំពោះវិនិយោគ ជាពិសេសក្នុងវិស័យដែលត្រូវការរយៈពេលវែងដើម្បីផ្តល់ផលចំណេញ (ឧទាហរណ៍វិស័យកសិកម្ម)។ នៅពេលសេដ្ឋកិច្ចរីកលូតលាស់ និងមានសកម្មភាពកាន់តែច្រើនមុខ ភាពទន់ខ្សោយនៃប្រព័ន្ធតុលាការ ក៏មានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើង។ ដំណោះស្រាយជាក់ស្តែងមួយ គឺត្រូវកសាងសមត្ថភាពយន្តការដោះស្រាយទំនាស់ ដែលមិនមែនជាប្រព័ន្ធតុលាការ ជាអាទិ៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រាប់ដោះស្រាយវិវាទឧស្សាហកម្ម ឬគណៈកម្មការសុរិយោដីសម្រាប់ដោះស្រាយជម្លោះដីធ្លី ជាដើម។ ការបង្កើតស្ថាប័នឯករាជ្យដាច់ពីតុលាការ មានន័យថា វិនិយោគនឹងមិនជួបឧបសគ្គដោយសារកង្វះសមត្ថភាពនៃប្រព័ន្ធតុលាការ ហើយតុលាការក៏នឹងមិនរងបន្ទុកធ្ងន់ដោយសារចំនួន និងភាពស្មុគស្មាញនៃករណីបណ្តឹងដែរ។ លើសពីនេះទៀត ស្ថាប័នឯកទេសដែលមានតម្លាភាព អាចជួយកាត់បន្ថយការចែកចាយព័ត៌មានទីផ្សារមិនស្មើភាព ជួយបង្កើនប្រសិទ្ធភាព និងកាត់បន្ថយហានិភ័យ ព្រមទាំងភាពមិនច្បាស់លាស់សម្រាប់វិនិយោគិន។

ស្ថិរភាព ជាកត្តាសំខាន់បំផុតក្នុងការកំណត់ស្ថានភាពសេដ្ឋកិច្ចរយៈពេលវែងរបស់ប្រទេសមួយ និងជាបុរេលក្ខខណ្ឌដ៏ចាំបាច់សម្រាប់វិនិយោគ។ កន្លងមក កម្ពុជាបានអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចយ៉ាងវៃឆ្លាត៖ បរិយាកាសទូទៅមានស្ថិរភាពល្អនិងអំណោយផលដល់វិនិយោគ អតិផរណាមានកម្រិតទាប ធនបម្រុងជារូបិយវត្ថុបរទេសកើនឡើងដល់ ២,៧ពាន់លានដុល្លារអាមេរិក នៅចុងឆ្នាំ២០១០ ហើយបំណុលសាធារណៈមានកម្រិតអាចគ្រប់គ្រងបាន។ ដោយសារស្ថិរភាពល្អ វិនិយោគផ្ទាល់ពីបរទេស (FDI) កើនបាន ៤២លានដុល្លារពីឆ្នាំ២០១០-២០១១ ថ្វីបើនៅទាបជាងល្បឿនកំណើនមុនពេលមានវិបត្តិសេដ្ឋកិច្ចក្តី។ មកទល់ពេលនេះ វិធានការឆ្លើយតបល្អរបស់ធនាគារជាតិនៃកម្ពុជា (ការតម្លើងថ្លៃប្រាក់រៀល និងការបង្កើនធនបម្រុងជារូបិយវត្ថុបរទេស) អាចគ្រប់គ្រងអតិផរណាបាន។ ប៉ុន្តែដោយសារកំណើនអត្រាអតិផរណាក្នុងតំបន់ និងសម្ពាធផុសចេញពីកំណើនសេដ្ឋកិច្ច លំហូរចូលមូលធន និងកំណើនចំណាយសាធារណៈ ដូច្នេះរដ្ឋាភិបាលត្រូវតែគ្រប់គ្រងអតិផរណាឲ្យបានតាមរយៈគោលនយោបាយដ៏សមស្រប។ កត្តាអាចបង្កអស្ថិរភាពសេដ្ឋកិច្ចមួយទៀត គឺការផ្តត់ផ្គង់ឥណទានដល់វិស័យឯកជនដែលបានកើនឡើង ៣០% ពីឆ្នាំ ២០០៩-២០១០ (ក្រាហ្វិក ២) ដែលត្រូវមានបទបញ្ញត្តិសម្រាប់កាត់បន្ថយហានិភ័យ និងគ្រប់គ្រងនិន្នាការឡើងថ្លៃទំនិញ។ ប្រភពនៃអស្ថិរភាពនយោបាយដូចជា ការទន្ទ្រានយកដី ការអភិវឌ្ឍទីក្រុងឡើងវិញ និងការឡើងថ្លៃអាហារ ក៏គួរតែដោះស្រាយដែរ។

ក្រាហ្វិក ២. កំណើនឥណទានសម្រាប់វិស័យឯកជន




ប្រភព៖ បទបង្ហាញក្នុងសន្និសីទចក្ខុវិស័យឆ្នាំ២០១១

## ការអភិវឌ្ឍកម្លាំងពលកម្ម

កម្ពុជា មានប្រជាជនវ័យក្មេងយ៉ាងច្រើន ដែលសកម្ម និងធ្វើការផ្លាស់ទីចុះឡើង។ បើសិនមានគោលនយោបាយសមស្រប ទ្រព្យសំណាងជាប្រជាជននេះ អាចក្លាយជាសម្បត្តិដ៏ស្តុកស្តម្ភសម្រាប់ជម្រុញ និងធ្វើពិពិធកម្មកំណើនសេដ្ឋកិច្ច។ តាំងពីដើមរៀងមក ថ្លៃពលកម្មទាបជាកត្តាសំខាន់មួយសម្រាប់ទាក់ទាញវិនិយោគទុនបរទេស ជាពិសេស ក្នុងវិស័យកម្មន្តសាល។ វិនិយោគនេះ បានផ្តល់ការងាររាប់ពាន់ ព្រមទាំងជាឈ្នាន់មួយសម្រាប់ការឈានឡើងផ្នែកឧស្សាហកម្ម។ ការពង្រឹងផលចំណេញទាំងនេះ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ត្រូវមានការជម្រុញជាគោលនយោបាយរួមមួយពីសំណាក់រដ្ឋាភិបាល។ គន្លឹះសំខាន់ គឺសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការផ្តល់កម្លាំងពលកម្មមានជំនាញដ៏ចាំបាច់សម្រាប់ជម្រុញពិពិធកម្ម ព្រមទាំងពង្រឹងវិស័យជាប្រពៃណី ដូចជា ទេសចរណ៍ និងផ្នែកកាត់ដេរជាដើម។

លក្ខខណ្ឌចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ចចម្រុះបែប គឺការបង្កើនផលិតភាពពលកម្មក្នុងវិស័យកសិកម្ម។ នាបច្ចុប្បន្ន ការរួមចំណែករបស់មនុស្សម្នាក់គិតក្នុងមួយឯកតាកំណើន ផសស មានលក្ខណៈមិនស្មើគ្នាទេរវាងវិស័យនានា ដោយឡែក ពលករក្នុងកសិកម្ម មានផលិតភាពតិចជាង ពលករក្នុងឧស្សាហកម្ម (មានផលិតភាពខ្ពស់ជាងគេ) ឬពលករក្នុងសេវាកម្ម។ រាជរដ្ឋាភិបាលបានផ្តោតកម្លាំងលើការបង្កើនផលិតភាពពលកម្ម ក្នុងកសិកម្ម ដោយធ្វើការផ្សព្វផ្សាយពីជំនាញថ្មីៗ បច្ចេកទេស និងផ្តល់ការបណ្តុះបណ្តាលដល់កម្លាំងពលកម្មនៅជនបទ។ ថវិកាជាតិបានជួយទ្រទ្រង់យ៉ាងច្រើនដល់ មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្មខេត្ត ដើម្បីផ្តល់កម្មវិធីបណ្តុះបណ្តាល អំពីវិធីសាស្ត្រដាំដុះ ផលិតកម្មជី ការរក្សាទុកកសិផលក្រោយពេលប្រមូលផល ការដាំដំណាំចម្រុះ និងជំនាញមូលដ្ឋាននៃសហគ្រិន។ ការបង្កើនផលិតភាពពលកម្មក្នុងវិស័យនេះ នឹងជះឥទ្ធិពលជម្រុញផលិតកម្មកសិកម្ម ព្រមទាំងជួយរំដោះកម្លាំងពលកម្មលើសតម្រូវការចេញពីវិស័យកសិកម្ម ឲ្យចូលបម្រើក្នុងឧស្សាហកម្ម និងសេវាកម្មដែលមានផលិតភាពខ្ពស់ជាង។

នាបច្ចុប្បន្ន កម្លាំងពលកម្មរបស់កម្ពុជានៅខ្វះខាតជំនាញដ៏ចាំបាច់សម្រាប់ពិពិធកម្មក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម ក្នុងនេះ គេចាំបាច់ត្រូវកែលម្អស្តង់ដារ និងបង្កើនលទ្ធភាពទទួលបានការអប់រំថ្នាក់ខ្ពស់ ដើម្បីដោះស្រាយ "ចន្លោះខ្វះខាតជំនាញនេះ"។ ស្ថាប័នអប់រំថ្នាក់ខ្ពស់ (HEIs) ជាច្រើននៅកម្ពុជា នៅទាបជាងស្តង់ដារអន្តរជាតិក្នុងវិស័យស្នូល ដូចជា ការស្រាវជ្រាវ អភិបាលកិច្ច និងការបង្រៀន។ បន្ថែមលើកង្វះសមត្ថភាពស្ថាប័ននេះ នៅមានកង្វះសម្ភារៈសម្រាប់ការស្រាវជ្រាវ និងការបង្រៀន ដូចជា សៀវភៅ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ទំនើប បន្ទប់ពិសោធន៍។ល។ អត្រាចុះឈ្មោះចូលរៀននៅជនបទ នៅទាបជាខ្លាំងជាងតំបន់ទីក្រុង ហើយជនវណ្ណៈខ្ពស់មានប្រៀបលើសលុបជាងគេ។ ជាដំណោះស្រាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ បានផ្តោតលើសមត្ថភាព និងដែនឈោងដល់នៃការអប់រំថ្នាក់ខ្ពស់ ដោយពង្រីកលទ្ធភាពទទួលបានការអប់រំ តាមរយៈកម្មវិធីអាហារូបករណ៍ និងការកែលម្អស្តង់ដារបង្រៀន និងការស្រាវជ្រាវតាមកម្មវិធីកសាងសមត្ថភាពផ្សេងៗ។ បទបញ្ញត្តិសមស្រប ក៏មានតួនាទីសំខាន់ដែរ មានជាអាទិ៍ ក្រមសីលធម៌ ស្តង់ដារនិងប្រព័ន្ធទទួលស្គាល់គុណភាពសម្រាប់លើកទឹកចិត្ត HEIs ឲ្យកែលម្អគុណភាព និងផ្តល់ព័ត៌មានកាន់តែច្រើនដល់និយោជក និងនិស្សិត អំពីមុខវិជ្ជា និងគុណភាពនៃសញ្ញាប័ត្ររបស់ខ្លួន។

បញ្ហាស្នូលមួយទៀត ទាក់ទិននឹងប្រសិទ្ធភាពទីផ្សារពលកម្ម គឺភាពមិនស៊ីគ្នារវាងជំនាញដែលវិស័យឯកជនស្វែងរកក្នុងទីផ្សារពលកម្ម និងជំនាញដែល HEIs ផ្គត់ផ្គង់។ បញ្ហានេះចោទជាពិសេស ក្នុងមុខជំនាញវិជ្ជាជីវៈមួយចំនួនដែលឧស្សាហកម្មប្រភេទខ្លះត្រូវការជាចាំបាច់។ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ជាក្របខ័ណ្ឌគោលនយោបាយពលកម្មរួមរបស់រដ្ឋាភិបាល សម្រាប់ផ្តល់ឲ្យទីផ្សារពលកម្មកម្ពុជានូវមុខជំនាញដែលនិយោជកចង់បាន។ គំនិតផ្តួចផ្តើមផ្សេងៗ រួមមានរបៀបវារៈកំណែទម្រង់នៃ គណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ការបង្កើត ទីភ្នាក់ងារជាតិមុខរបរ (NEA) និងគម្រោងពង្រឹង ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (STVET) ដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី។ មានបញ្ហាប្រឈមជាច្រើនសម្រាប់ TVET ជាពិសេសទស្សនៈក្នុងសង្គមដែលថា TVET ជាវគ្គបណ្តុះបណ្តាលសម្រាប់ពលករសាមញ្ញ មិនមែនអ្នកមានជំនាញវិជ្ជាជីវៈទេ។ គោលនយោបាយរបស់រដ្ឋាភិបាល ត្រូវផ្តោតលើការកែប្រែទស្សនៈទាំងនេះ តាមរយៈបទបញ្ញត្តិសមស្រប និងប្រព័ន្ធទទួលស្គាល់គុណភាពអប់រំ។

## ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

ក្នុងមួយទសវត្សរ៍កន្លងទៅនេះ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងអគ្គិសនីនៅកម្ពុជា មានការអភិវឌ្ឍយ៉ាងច្រើន។ លទ្ធផលទាំងនេះ ភាគច្រើនបានមកពីកិច្ចសហប្រតិបត្តិការក្នុងតំបន់ តាមរយៈគំនិតផ្តួចផ្តើមមហាអនុតំបន់មេគង្គដែលគាំទ្រដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB-GMS)។ ត្រឹមចុងឆ្នាំ២០០៨ ADB បានផ្តល់មូលនិធិ ៤១៨លានដុល្លារ សម្រាប់ទ្រទ្រង់ដល់គម្រោងទាំងអស់ ៩។ គំនិតផ្តួចផ្តើម ADB-GMS កន្លងមក សំខាន់ជាខ្លាំងសម្រាប់ការអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង (SEC) ដោយបានកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត តភ្ជាប់ប្រទេសកម្ពុជាទៅថៃ វៀតណាម និង ឡាវ។ បច្ចុប្បន្ន កម្ពុជាកំពុងស្តារជួសជុសបណ្តាញផ្លូវដែកដែលចាស់ទ្រុឌទ្រោម ដោយមានការគាំទ្រពី ADB និងវិនិយោគពីវិស័យឯកជន។ គម្រោងមានតម្លៃ ១៤៨លានដុល្លារនេះ នឹងតភ្ជាប់ប្រទេសកម្ពុជា ទៅថៃ និងវៀតណាម ហើយក្លាយជាចំណែកដ៏សំខាន់មួយនៃផ្លូវដែក តភ្ជាប់ពីសិង្ហបុរីទៅក្រុងគុនមីង (Kunming) នៃខេត្តយូន់ណាន (Yunnan) ប្រទេសចិន។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវគោក និងផ្លូវដែក នឹងជួយឲ្យកម្ពុជាអាចធ្វើសមាហរណកម្មកាន់តែប្រសើរទៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ ដោយអាចបង្កើនតម្លៃបន្ថែម និងចូលទៅកាន់ទីផ្សារថ្មីៗ។

សមត្ថភាពផ្គត់ផ្គង់ភស្តុភារ (logistics) នាពេលបច្ចុប្បន្ន បានរាំងស្ទះដល់ការសម្រេចបាន នូវសក្តានុពលនៃហេដ្ឋារចនាសម្ព័ន្ធដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស។ បញ្ហាផ្សេងៗ ដូចជា យានយន្តចាស់ហួសសម័យ និងនីតិវិធីគយ បានបង្កើនរយៈពេល និងបន្ទុកចំណាយ លើការនាំចេញរបស់កម្ពុជា។ នេះជាឧបសគ្គដ៏ធំមួយដល់ការអភិវឌ្ឍ SMEs ដែលត្រូវការច្រកចេញចូលទៅកាន់ទីផ្សារពិភពលោកមានសន្ទុះល្អ អាចទុកចិត្តបាន និងមានតម្លៃសមរម្យ។ ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទំនើប អាចដោះស្រាយតម្រូវការនេះបាន។ ការកែសម្រួលតម្រឹមនីតិវិធីគយ ការអនុវត្តច្បាប់ និងបទបញ្ញត្តិដែលច្បាស់លាស់ និងការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ត្រួតពិនិត្យទំនិញ មុនពេលទៅដល់ព្រំដែន (ឧ. កន្លែងត្រួតពិនិត្យទំនិញផ្លូវគោក) អាចបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា នៅក្នុងទីផ្សារពិភពលោក។ សមត្ថភាពមានកម្រិតនៃ វិស័យដឹកជញ្ជូនឆ្លងកាត់ព្រំដែនដែលចាស់ហួសសម័យ ក៏ធ្វើឲ្យកម្ពុជាថយចុះសមត្ថភាពប្រកួតប្រជែងក្នុងការនាំចេញដែរ។ ស្តង់ដារយានយន្តកម្រិតទាប និងកង្វះវិនិយោគ បង្កបន្ទុកចំណាយខ្ពស់ក្នុងការដឹកជញ្ជូនទំនិញគិតក្នុង ១គីឡូក្រាម ភាពមិនប្រាកដប្រជាលើរយៈពេល និងសុវត្ថិភាពនៃការបញ្ជូនទំនិញ។ ដូច្នេះ ត្រូវមានបទបញ្ញត្តិជម្រុញការប្រកួតប្រជែងក្នុងផ្នែកដឹកជញ្ជូន ដើម្បីលើកទឹកចិត្តប្រតិបត្តិករឲ្យបង្កើនស្តង់ដារគុណភាពនៃការដឹកជញ្ជូន។

ផលិតផលកម្មន្តសាល បានកើនឡើង ហើយលំនាំនៃចំណាយប្រើប្រាស់ បានប្រែប្រួលស្របតាមកំណើនសេដ្ឋកិច្ច ដែលនាំឲ្យតម្រូវការអគ្គិសនីកើនឡើងយ៉ាងខ្លាំង។ កំណើនដ៏ខ្ពស់ក្នុងការប្រើប្រាស់អគ្គិសនី (១៩% គិតនៅក្នុងកម្ពុជាទាំងមូល និង ២៥% នៅភ្នំពេញ) បង្ហាញពីតម្រូវការអភិវឌ្ឍសមត្ថភាពផ្គត់ផ្គង់អគ្គិសនីដើម្បីតាមឲ្យទាន់តម្រូវការនាពេលអនាគត។ ដើម្បីបំពេញតម្រូវការបច្ចុប្បន្ន និងទៅអនាគត រដ្ឋាភិបាលបានកំណត់ចំណុចសំខាន់៣ ដែលត្រូវយកចិត្តទុកដាក់ខាងគោលនយោបាយ៖

ទី១ ដោយសារកម្ពុជាត្រូវនាំចូលថាមពលអគ្គិសនី ៤២% ពីបរទេស ដូច្នេះត្រូវបន្តអនុវត្តគោលនយោបាយ ក្របខ័ណ្ឌស្ថាប័ន និងបទបញ្ញត្តិ ព្រមទាំងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដើម្បីធានាឲ្យមានថាមពលនាំចូលតម្លៃថោក និងផ្គត់ផ្គង់ទៀងទាត់ក្នុងរយៈពេលខ្លី។

ទី២ ត្រូវមានធ្វើវិនិយោគយ៉ាងសកម្មក្នុងផ្នែកវារីអគ្គិសនី ដើម្បីប្រើប្រាស់សក្តានុពលដ៏ធំធេងនៃផ្លូវទឹកនៅកម្ពុជា ក្នុងការផ្តល់ថាមពលអគ្គិសនី។ ជាយុទ្ធសាស្ត្ររយៈពេលមធ្យម និងរយៈពេលវែង គឺត្រូវអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដើម្បីទាញយកផលពីសម្បត្តិធម្មជាតិដ៏ស្តុកស្តម្ភដែលតាមការប៉ាន់ស្មាន មានសក្តានុពលអាចផ្តល់ថាមពលវារីអគ្គិសនី ដល់ទៅ ១០.០០០ មេហ្គាវ៉ាត់ និងដែលបច្ចុប្បន្នផ្តល់បានតែ ៣% នៃអគ្គិសនីប្រើប្រាស់ប៉ុណ្ណោះ។ សព្វថ្ងៃ កម្ពុជាមានផែនការដ៏ធំមួយ ដើម្បីបង្កើនសមត្ថភាពវារីអគ្គិសនី ហើយក្នុងរយៈពេលវែងសង្ឃឹមថានឹងអាចទទួលបានចំណូលពីការនាំចេញថាមពលទៅប្រទេសជិតខាងក្នុងមហាអនុតំបន់មេគង្គ (GSM)។

ទី៣ ការផ្គត់ផ្គង់អគ្គិសនី ត្រូវពង្រីកឲ្យហួសពីតំបន់មានប្រជាជនកុះករ ទៅដល់ជនបទកម្ពុជា។ សកម្មភាពនេះ នឹងជួយលើកកម្ពស់កម្រិតជីវភាព និងបង្កើនផលិតភាពកសិកម្ម។ រដ្ឋាភិបាល បានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតាមួយចំនួន ដើម្បីដោះស្រាយបញ្ហាភ្ជាប់បណ្តាញអគ្គិសនីនៅជនបទ ពោលគឺត្រឹមឆ្នាំ២០៣០ គេសង្ឃឹមថា គ្រួសារនៅជនបទប្រមាណ ៧០% ទទួលបានការផ្គត់ផ្គង់អគ្គិសនីប្រកបដោយគុណភាព និងត្រឹមឆ្នាំ២០២០ គ្រប់ភូមិទាំងអស់ត្រូវទទួលបានសេវាកម្មអគ្គិសនី។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋាភិបាលត្រូវបង្កើនប្រវែងខ្សែកាបបញ្ជូនចរន្តអគ្គិសនី ឲ្យបានវែងជាង ២១០០គីឡូម៉ែត្រត្រឹមឆ្នាំ២០២០ ដោយគ្រោងចំណាយថវិកាអស់ ៥០០លានដុល្លារក្នុង៥ឆ្នាំខាងមុខ។

នាបច្ចុប្បន្ន រដ្ឋាភិបាលក៏កំពុងដោះស្រាយបញ្ហាមួយចំនួនពាក់ព័ន្ធនឹងច្រើនវិស័យ ដែលជាផ្នែកមួយនៃក្របខ័ណ្ឌគោលនយោបាយថាមពលរួម។ បញ្ហាសំខាន់បំផុត គឺត្រូវចាត់វិធានការដើម្បីធានាឲ្យការផ្គត់ផ្គង់ និងប្រភពថាមពលនាពេលអនាគត មានចីរភាពខាងសេដ្ឋកិច្ចផង និងមានចីរភាពខាងសង្គម និងបរិស្ថានផង។ រដ្ឋាភិបាលត្រូវព្យាយាមលើកទឹកចិត្តឲ្យមានការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថានដោយសារការប្រើប្រាស់ថាមពល។ ម៉្យាងទៀត ត្រូវបង្កើនការស្រាវជ្រាវពីផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច និងបរិស្ថាន នៃការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពល និងប្រសិទ្ធភាពគោលនយោបាយពាក់ព័ន្ធ ហើយផ្តល់ទៅជូនរដ្ឋាភិបាល ដើម្បីពិចារណាដាក់បញ្ចូលទៅក្នុងគោលនយោបាយនាពេលអនាគត។

*តទៅទំព័រ ១១*

*Council and Board of Governors and District Council and Board of Governors* ( Phnom Penh: RGC )

Royal Government of Cambodia ( 2009b ), *Sub-decree no. 218 ank.bk on the Establishment, Organization and Functioning of the Technical Facilitation Committee of the Provincial, Municipal and District Council* ( Phnom Penh: RGC )

Royal Government of Cambodia ( 2009c ), *Sub-decree no. 219 ankr.bk on the development and 3 year rolling investment plan for the capital, provnices, municipalities, districts, and khans* ( Phnom Penh: RGC )

Thon, Vimealea, Heng Seiha, Kruy Virak & Ly Tem ( 2011 ), "Assessment of One Window Service Office and District Ombudsman Pilot Project", *Annual Development Review 2010-11* ( Phnom Penh: CDRI )

## *តពីទំព័រ ៥* **ជម្រុញកំណើនសេដ្ឋកិច្ចខ្ពស់ ...**

ក្រាហ្វិក ៣. ការប៉ាន់ស្មានពីការពង្រីកបណ្ដាញចែកចាយថាមពល




ប្រភព៖ បទបង្ហាញក្នុងសន្និសីទចក្ខុវិស័យឆ្នាំ២០១១

### ការប្រមើលឃើញ និងអាទិភាព

សេដ្ឋកិច្ចកម្ពុជា បានងើបឡើងវិញល្អគួរឲ្យកត់សម្គាល់ពីការប៉ះទង្គិចដោយវិបត្តិសេដ្ឋកិច្ចសាកល។ កំណើនសេដ្ឋកិច្ច មានសន្ទុះខ្លាំង និងរំពឹងថានៅថេរក្នុងរយៈពេលពីរបីឆ្នាំខាងមុខ។ ប៉ុន្តែឥឡូវនេះ ត្រូវត្រៀមរៀបចំខ្លួនជាបន្ទាន់សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីកសាងសេដ្ឋកិច្ចលើគ្រឹះដ៏រឹងមាំ ធ្វើពិពិធកម្មសេដ្ឋកិច្ច និងរៀបចំប្រទេសដើម្បីទទួលបានកំណើនខ្ពស់ ប្រកបដោយចីរភាព និងសមធម៌។ រាជរដ្ឋាភិបាលមានគោលគំនិតច្បាស់លាស់ពីបញ្ហាត្រូវប្រឈមមុខ និងមានឆន្ទៈចង់ដោះស្រាយ ចង់បំបាត់ឧបសគ្គ តាមការអនុវត្តគោលនយោបាយផ្ដោតចំគោលដៅ និងមានការសម្របសម្រួល។ កង្វះសមត្ថភាពស្ថាប័ន បានរារាំងគោលនយោបាយមិនឲ្យសម្រេចបានតាមគោលដៅកំណត់ទុក ហើយវាជាឧបសគ្គដែលគេបានគូសបញ្ជាក់ជាច្រើនលើកក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១១។ ការយកចិត្តទុកដាក់របស់រដ្ឋាភិបាល ក្នុងការរៀបចំច្បាប់ បទបញ្ញត្តិ និងបង្កើតក្របខ័ណ្ឌគោលនយោបាយប្រកបដោយ គំនិតបែបថ្មី បានបើកចំហប្រទេសកម្ពុជា និងសម្រេចបានកំណើន និងវិបុលភាពកម្រិតខ្ពស់មិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ប៉ុន្តែ ដើម្បីឲ្យកំណើននេះអាចបន្តទៅមុខ និងមានតម្លាភាព ស្ថាប័ននានាដែលបានកសាងឡើងលើគោលការណ៍អភិបាលកិច្ចល្អ ត្រូវអនុវត្តតាមគោលនយោបាយបានរៀបចំឡើង ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចចម្រុះ ប្រកបដោយចីរភាព និងសមភាព។ ទោះបីតាមការបង្កើតបទបញ្ញត្តិគ្រប់គ្រងទីផ្សារឥណទាន ឬតាមការអនុវត្តកម្មវិធី TVET យ៉ាងសក្ដិសិទ្ធិក្ដី សមត្ថភាពស្ថាប័នសំខាន់ណាស់ក្នុងការធានាឲ្យមានការអនុវត្ត និងពង្រឹង គោលនយោបាយនានារបស់រដ្ឋាភិបាល និងការតាមដានលទ្ធផល។

ការពង្រឹងសមត្ថភាពស្ថាប័នរបស់កម្ពុជា ត្រូវមានការកសាងសមត្ថភាពក្នុងរយៈពេលវែង និងការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ក្នុងទិសដៅដែលបានដាក់ចេញ។ ប៉ុន្តែតាមធម្មតា ការងារនេះតែងជួបការលំបាកដោយសារភាពមិនស៊ីគ្នារវាងការរំពឹងទុករបស់ដៃគូអភិវឌ្ឍន៍ និងភាពជាក់ស្ដែងនៃសមត្ថភាពស្ថាប័ន។ ជាទូទៅ ដៃគូអភិវឌ្ឍន៍តែងរំពឹងចង់បានលទ្ធផលឆាប់រហ័ស ប៉ុន្តែភាពទន់ខ្សោយជាប្រព័ន្ធជាក់ស្ដែងក្នុងស្ថាប័នកម្ពុជា ត្រូវការពេលវេលាយូរ ដើម្បីដោះស្រាយ។ សមត្ថភាពស្ថាប័ន មិនមែនត្រឹមតែជាបញ្ហាសេដ្ឋកិច្ច-សង្គមកិច្ចនោះទេ ប៉ុន្តែ មានទាក់ទងនឹងទិដ្ឋភាពនយោបាយ ព្រមទាំងវប្បធម៌សំខាន់ៗទៀតផង ហើយបញ្ហាទាំងនេះមិនអាចដោះស្រាយបានភ្លាមៗនោះទេ។ ដើម្បីឲ្យមានប្រសិទ្ធភាពល្អ ការរំពឹងទុក និងភាពជាក់ស្ដែង ត្រូវតែសម្របសម្រួលឲ្យស៊ីគ្នា តាមរយៈអន្តរាគមន៍ខាងគោលនយោបាយដ៏សមស្រប។ រដ្ឋាភិបាលយល់ឃើញដោយប្រាកដនិយមថា ការកសាងសមត្ថភាពស្ថាប័ន ត្រូវប្រើពេលពី ៥-១០ឆ្នាំ ដើម្បីឈានដល់ស្តង់ដារស្ថាប័នសាកល ហើយដៃគូអភិវឌ្ឍន៍នានា គួរតែអនុវត្តការងារ ព្រមទាំងរៀបចំ និងសម្របសម្រួលគោលនយោបាយឆ្លើយតបឲ្យស៊ីគ្នានឹងក្របខ័ណ្ឌពេលវេលានេះ។

### ឯកសារយោង

បទបង្ហាញនានាក្នុងសន្និសីទចក្ខុវិស័យ អាចរកបាននៅក្នុងគេហទំព័ររបស់វិទ្យាស្ថាន CDRI: www.cdri.org.kh។